# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ROYAL UNIVERSITY OF LAW AND ECONOMIC


## គម្រោងស្រាវជ្រាវ

# កម្មវិធីសប្បុរសធម៌ ទៅកាន់សាលាបឋមសិក្សា ដំណាក់ក្របី ឃុំកោះស្ដេច ស្រុកគិរីសាគរ ខេត្តកោះកុង

ការស្រាវជ្រាវពីថ្ងៃទី ១ ខែ តុលា ឆ្នាំ២០២៥ ដល់ថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០២៦


រៀបរៀងដោយ៖

និស្សិតឈ្មោះ: អ្នកស្រី **ហោ សុគន់**

កញ្ញា **ធិន វល្លក្ខ**

កញ្ញា **ហេង សុបញ្ញា**

កញ្ញា **សៀក គឹមហ៊ួង**

កញ្ញា **អេក ម៉ៃកណិការ**

លោក **ចន ប៊ុនធាន**

លោក **ឆុង វិបុល**

លោក **ឡុង សំណាង**

បង្រៀនដោយ

**បណ្ឌិត ព្រុំ ទេវី**


ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ គ្រប់គ្រងធុរកិច្ច

ឯកទេស គ្រប់គ្រង ជំនាន់២២ ជំហាន១

ឆ្នាំចូលសិក្សា ២០២៥

ឆ្នាំសរសេរ ២០២៦

# មាតិកា

**សារគតគម្រោង**..................................................................................i

## ជំពូកទី១

## ការរៀបចំផែនការគម្រោង

១.១. អំពីគម្រោង ..................................................................................1
១.២. គោលបំណង..................................................................................1
១.៣. គោលដៅ..................................................................................1
១.៤. សកម្មភាពសំខាន់ៗ..................................................................................1
១.៥. ប្រភពថវិកា ..................................................................................2
១.៦. អ្នកទទួលខុសត្រូវក្នុងគម្រោង..................................................................................3
១.៧. សូចនាករ ..................................................................................4
១.៨. មធ្យោបាយផ្ទៀងផ្ទាត់ ..................................................................................6
១.៩. ហានិភ័យ..................................................................................8

## ជំពូកទី២

## ដំណើរការអនុវត្តន៍គម្រោង និងការជ្រើសរើសធនធានមនុស្ស

២.១. ការជ្រើសរើសធនធានមនុស្ស..................................................................................11
២.២. ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៃគម្រោង..................................................................................11
២.២.១. ការរៀបចំអង្គការលេខ..................................................................................12
២.២.២. តួនាទី និងទំនួលខុសត្រូវ..................................................................................14
២.២.៣. ការប្រើប្រាស់ពេលវេលា..................................................................................14
២.៤ ការប្រើប្រាស់ប្រធានគម្រោង..................................................................................16
២.៥. ការតាមដានត្រួតពិនិត្យគម្រោង..................................................................................17
២.៥.១. ការតាមដានគម្រោង ..................................................................................17
២.៥.២. ការវាយតម្លៃគម្រោង ..................................................................................17
២.៥.៣. ការតាមដានបន្ត..................................................................................18
២.៦. ការបញ្ចប់គម្រោង..................................................................................18

២.៦.១. ការបញ្ចប់គម្រោង ........ 18
២.៦.២. ការផ្ទេរនិរន្តភាពនៃគម្រោង ........ 18

## ជំពូកទី៣

## ការវិភាគ SWOTលើដំណើរការអនុវត្តន៍គំរោង

៣.១. ចំណុចខ្លាំង ........ 19
៣.២. ចំណុចខ្សោយ ........ 20
៣.៣. ឱកាស ........ 20
៣.៤. ការគំរាមកំហែង ........ 21
**សេចក្តីសន្និដ្ឋាន** ........ 22

# សារចនាគម្រោង

ក្នុងបរិបទសង្គមបច្ចុប្បន្ន ប្រទេសកម្ពុជាកំពុងឆ្ពោះទៅរកការអភិវឌ្ឍន៍យ៉ាងឆាប់រហ័សក្នុងវិស័យសេដ្ឋកិច្ច ការអប់រំ និងសុខុមាលភាពសង្គម។ ទោះជាយ៉ាងណាក៏ដោយ តាមតំបន់ជនបទជាច្រើននៅតែប្រឈមមុននឹងបញ្ហាខ្វះខាត និងប៉ះពាល់ដល់ជីវភាពប្រជាពលរដ្ឋជាបន្តបន្ទាប់។ ក្នុងចំណោមតំបន់ទាំងនេះសាលាបឋមសិក្សាដំណាក់ក្របី ឃុំកោះស្តេច ស្រុកគិរីសាគរ ខេត្តកោះកុង គឺជាតំបន់មួយដែលគ្រូបង្រៀន សិស្សានុសិស្សនៅតែខ្វះខាតសម្ភារៈសិក្សា ឯកសារបង្រៀន និងបរិក្ខារសិក្សាផ្សេងៗ។ កត្តាទាំងនេះបានបង្កើតឱ្យមានបញ្ហាជាច្រើនទៅដល់លទ្ធផលសិក្សា និងការចូលសិក្សារសម្រាប់កុមារផងដែរ។

ក្នុងការយល់ដឹងអំពីបញ្ហានេះអោយកាន់តែស៊ីជម្រៅក្រុមនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងធុរៈកិច្ច ឯកទេសគ្រប់គ្រងជំនាន់២២ជំហាន១(MBM22-1B)នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានរៀបចំនូវគម្រោងសប្បុរសធម៌មួយដែលមានឈ្មោះថា "**កម្មវិធីសប្បុរសធម៌ ទៅកាន់សាលាបឋមសិក្សា ដំណាក់ក្របី ឃុំកោះស្តេច ស្រុកគិរីសាគរ ខេត្តកោះកុង**"។ គោលបំណងសំខាន់របស់គម្រោងនេះ គឺដើម្បីចែក សម្ភារៈសិក្សា បរិក្ខារសាលារៀន និងឧបត្ថម្ភផ្សេងៗទៅដល់សិស្សានុសិស្សនៅសាលាបឋមសិក្សាដំណាក់ក្របីដែលកំពុងមានការខ្វះខាតពិតប្រាកដ។ ម្យ៉ាងវិញទៀត គម្រោងនេះក៏មានបំណងដើម្បីលើកកម្ពស់ស្មារតីចូលរួមស្ម័គ្រចិត្តរបស់ និស្សិតនិងជួយពង្រឹងទំនាក់ទំនងរវាងសាកលវិទ្យាល័យ និងសហគមន៍ក្នុងតំបន់ជនបទតាមខេត្តផងដែល។ លើសពីនេះ កម្មវិធីសប្បុរសធម៌នេះក៏ជាឱកាសសម្រាប់និស្សិតអនុវត្តន៍ចំណេះដឹងពិតប្រាកដ ដូចជាការរៀបចំផែនការគម្រោង ការបែងចែកភារកិច្ច ការគ្រប់គ្រងថវិកា ការស្វែងរកឧបត្ថម្ភ ការរៀបចំរបាយការណ៍ និងរបៀបធ្វើការជាមួយសហគមន៍ក្នុងតំបន់ជនបទតាមខេត្ត។

ដើម្បីធានាថាគម្រោងអនុវត្តបានប្រសើរបំផុត គម្រោងត្រូវបានបែងចែកជាបីវគ្គសំខាន់ៗគឺ ៖

- វគ្គទី១ : ការរៀបចំផែនការកម្មវិធី និងចុះសិក្សាព័ត៌មាននៅតំបន់
- វគ្គទី២ : ការដឹកជញ្ជូន និងចែកសម្ភារៈសិក្សារបស់ក្រុមនិស្សិតយើងខ្ញុំនឹងធ្វើដំណើរទៅកាន់សាលាបឋមសិក្សាដំណាក់ក្របី
- វគ្គទី៣ : ការសិក្សាវាយតម្លៃលទ្ធផល និងរៀបចំរបាយការណ៍ចុងក្រោយ។

គម្រោងនេះមិនមែនជាគ្រាន់តែការអនុវត្តកិច្ចការសិក្សានោះទេ ប៉ុន្តែជាការបង្ហាញពីទឹកចិត្តសប្បុរស ការយកចិត្តទុកដាក់ និងការចង់ចូលរួមសកម្មភាពសង្គមរបស់និស្សិតជំនាន់ថ្មី។ វាជាការចូលរួមតូចតាច ប៉ុន្តែមានន័យសំខាន់ក្នុងការគាំទ្រសិស្សានុសិស្សដែលមានតម្រូវការចំបាច់ និងជួយអភិវឌ្ឍសហគមន៍តាមរយៈការអប់រំដែលមានប្រសិទ្ធិភាព។

# ជំពូកទី១
# ការរៀបចំផែនការគម្រោង

# ជំពូកទី១
# ការរៀបចំផែនការគម្រោង

## ១.១. អំពីគម្រោង

គម្រោងនេះមានឈ្មោះថា៖ "**កម្មវិធីសប្បុរសធម៌ ទៅកាន់សាលាបឋមសិក្សា ដំណាក់ក្របី ឃុំកោះស្ដេច ស្រុកគិរីសាគរ ខេត្តកោះកុង**" ។

## ១.២. គោលបំណង

សម្រាប់គម្រោងមួយនេះដែរគឺ មានគោលបំណងដើម្បីធ្វើការចូលរួមជួយសម្រួលដល់ជីវភាព និង លើកទឹកចិត្តសិស្សានុសិស្សនៅក្នុងសាលាបឋមសិក្សាដំណាក់ក្របី ឃុំកោះស្ដេច ស្រុកគិរីសាគរ ខេត្តកោះកុង តាមរយៈការផ្តល់អំណោយសប្បុរសធម៌ជាសម្ភារៈសិក្សាដែលចាំបាច់ និង ថវិកាសម្រាប់ការអភិវឌ្ឍន៍ហេដ្ឋានរចនាសម្ព័ន្ធរបស់សាលារៀន។

## ១.៣. គោលដៅ

ដើម្បីសម្រេចឱ្យបាននូវគោលបំណងខាងលើនេះ គម្រោងបានកំណត់គោលដៅចំនួន ៣ជាចម្បង ដូចខាងក្រោម ៖

**គោលដៅទី១** : បង្កើតក្រុមការងារ សិក្សាពីតម្រូវការសម្ភារៈ និង រៀបចំផែនការកម្មវិធីសប្បុរសធម៌ ចាប់ពីសប្តាហ៍ទី១ ខែកុម្ភៈ ឆ្នាំ២០២៦ ដល់ សប្តាហ៍ទី១ ខែមីនា ឆ្នាំ២០២៦។

**គោលដៅទី២** : ដឹកជញ្ជូនសម្ភារៈទៅកាន់ទីតាំងរៀបចំកម្មវិធីសប្បុរសធម៌ និងរៀបចំប្រគល់កញ្ចប់អំណោយជូនដល់សិស្សានុសិស្ស និងចូលរួមថតរូបជាអនុស្សាវរីយ៍ ជាមួយលោកគ្រូអ្នកគ្រូ សិស្សានុសិស្សនៅត្រឹមសប្តាហ៍ទី១ ខែមីនា ឆ្នាំ២០២៦។

**គោលដៅទី៣** : សរសេររបាយការណ៍អំពី ការចំណាយ និងលទ្ធផលនានានៃគម្រោង ដើម្បីដាក់ជូន ទៅកាន់អ្នកពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី៣ ខែមីនា ឆ្នាំ២០២៦។

## ១.៤. សកម្មភាពសំខាន់ៗ

ដើម្បីសម្រេចបាននូវគោលដៅនីមួយៗនៃគម្រោងមួយនេះ យើងមានសកម្មភាពសំខាន់ៗមួយចំនួនសម្រាប់ ចូលរួមសម្រេចនូវគោលដៅទាំងបីខាងលើ ដែលមានដូចខាងក្រោម ៖

**គោលដៅទី១** : បង្កើតក្រុមការងារ សិក្សាពីតម្រូវការសម្ភារៈ និង រៀបចំផែនការកម្មវិធីសប្បុរសធម៌ ចាប់ពីសប្តាហ៍ទី១ ខែកុម្ភៈ ឆ្នាំ២០២៦ ដល់ សប្តាហ៍ទី១ ខែមីនា ឆ្នាំ២០២៦។

- **សកម្មភាពទី១.១** : បង្កើតក្រុមការងារដែលមានសមាជិក ៨ នាក់ ដើម្បីគ្រប់គ្រង និង អនុវត្ត គម្រោង នៅត្រឹមសប្តាហ៍ទី១ ខែកុម្ភៈ ឆ្នាំ២០២៦។

- **សកម្មភាពទី១.២** : ក្រុមការងារធ្វើការសិក្សា និងកំណត់ពីតម្រូវការសម្ភារៈដាក់ស្តែងរបស់សិស្សានុសិស្ស នៅត្រឹមសប្តាហ៍ទី២ ខែកុម្ភៈ ឆ្នាំ២០២៦។
- **សកម្មភាពទី១.៣** : ក្រុមការងាររៀបចំ និងវេចខ្ចប់កញ្ចប់អំណោយចំនួន១០០កញ្ចប់ សម្រាប់ប្រគល់ ជូនសិស្សានុសិស្ស នៅត្រឹមសប្តាហ៍ទី៣ ខែ កុម្ភៈ ឆ្នាំ២០២៦។

**គោលដៅទី២** : ដឹកជញ្ជូនសម្ភារៈទៅកាន់ទីតាំងរៀបចំកម្មវិធីសប្បុរសធម៌ និង រៀបចំប្រគល់កញ្ចប់អំណោយដល់សិស្សានុសិស្ស និងចូលរួមថតរូបជាអនុស្សាវរីយ៍ ជាមួយលោកគ្រូអ្នកគ្រូ សិស្សានុសិស្សនៅត្រឹមសប្តាហ៍ទី១ ខែមីនា ឆ្នាំ២០២៦។

- **សកម្មភាពទី២.១** : ក្រុមការងារ ដឹកជញ្ជូនកញ្ចប់អំណោយចំនួន១០០ កញ្ចប់ ទៅកាន់ទីតាំងដែល បានកំណត់ នៅត្រឹមសប្តាហ៍ទី៣ ខែ កុម្ភៈ ឆ្នាំ២០២៦ ។
- **សកម្មភាពទី២.២** : ក្រុមការងាររៀបចំ និងប្រគល់កញ្ចប់អំណោយចំនួន១០០ កញ្ចប់ ទៅកាន់សិស្សានុសិស្ស នៅត្រឹមសប្តាហ៍ទី១ ខែមីនា ឆ្នាំ២០២៦។
- **សកម្មភាពទី២.៣** : ក្រុមការងារ ផ្តិតយករូបភាពយ៉ាងតិច២០០រូប និង វីដេអូអនុស្សាវរីយ៍ យ៉ាងតិច ចំនួន១០វីដេអូ នៃសកម្មភាពគម្រោងនៅត្រឹម**សប្តាហ៍ទី១ ខែមីនា ឆ្នាំ២០២៦ ។**

**គោលដៅទី៣** : សរសេររបាយការណ៍អំពី ការចំណាយ និងលទ្ធផលនានានៃគម្រោង ដើម្បីដាក់ជូនទៅកាន់អ្នកពាក់ព័ន្ធ នៅត្រឹម**សប្តាហ៍ទី៣ ខែមីនា ឆ្នាំ២០២៦។**

- **សកម្មភាពទី៣.១** : ក្រុមការងារធ្វើរបាយការណ៍បូកសរុបចំណាយដែលបានចំណាយសម្រាប់គម្រោង ទាំងមូលនៅត្រឹមសប្តាហ៍ទី២ ខែមីនា ឆ្នាំ២០២៦ ។
- **សកម្មភាពទី៣.២** : ក្រុមការងារធ្វើរបាយការណ៍បូកសរុបនូវលទ្ធផលនានានៃគម្រោង នៅត្រឹមសប្តាទី២ ខែមីនា ឆ្នាំ២០២៦ ។
- **សកម្មភាពទី៣.៣** : ក្រុមការងារ ប្រគល់របាយការណ៍បូកសរុបចំណាយ និង លទ្ធផលនៃគម្រោងជូនទៅកាន់អ្នកដែលពាក់ព័ន្ធនៅត្រឹមសប្តាហ៍ទី៣ ខែមីនា ឆ្នាំ២០២៦។

## ១.៥. ប្រភពថវិកា

គម្រោងខាងលើនេះ ទទួលបានថវិកាគាំទ្រពីដៃគូរសហការរួមមានខាងក្រោម ៖

**គោលដៅទី១** : បង្កើតក្រុមការងារ សិក្សាពីតម្រូវការសម្ភារៈ និង រៀបចំផែនការកម្មវិធីសប្បុរសធម៌ ចាប់ពីសប្តាហ៍ទី១ ខែកុម្ភៈ ឆ្នាំ២០២៦ ដល់ សប្តាហ៍ទី១ ខែមីនា ឆ្នាំ២០២៦។ កញ្ចប់ថវិកាឧបត្ថម្ភ ទទួលបានពីសំណាក់ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឯកទេសគ្រប់គ្រង ជំនាន់ទី២២ និងតាមរយៈនិស្សិតនៃថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៃសាលកវិទ្យាសាស្ត្រភូមិន្ទនីតិសាស្ត្រ និង

វិទ្យាសាស្ត្រសេដ្ឋកិច្ចចំនួន ៤ ០០០ ០០០រៀល សម្រាប់ប្រើប្រាស់ក្នុងចំណាយទូទៅចំណា- យលើកញ្ចប់អំណោយ និងការវេចខ្ចប់។

**គោលដៅទី២** : កញ្ចប់ថវិកាឧបត្ថម្ភ ពីសំណាក់សប្បុរសជន(ប្រព័ន្ធfacebook)ដែលចាប់អារម្មណ៍ជាមួយគម្រោងនេះ និង ការចូលរួមពី អ្នកគ្រូ លោកគ្រូ រួមទាំង សិស្សច្បងសរុបជាថវិកាចំនួន ១ ០០០ ០០០រៀល និងតាមរយៈការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល(ធនាគារ និង មីក្រូហិរញ្ញវត្ថុ) សម្រាប់ប្រើប្រាស់ជាប្រាក់ឧបត្ថម្ភផ្ទាល់ជូនសាលារៀនគោលដៅ។

**គោលដៅទី៣** : ថវិកាបម្រុងរដ្ឋបាលគឺ ត្រូវដកចេញពី ៥% ទៅ ១០%នៃថវិកាសរុបដែលកៀរគរបាន ដើម្បីទុកសម្រាប់ចំណាយលើការរៀបចំរបាយការណ៍ ការបោះពុម្ព និងការបង់ថ្លៃសេវាសាធារណៈជូន ៦០ ០០០រៀល។ ហើយចំពោះថវិកាដែលនៅសេសសល់ពីកម្មវិធី ប្រសិន បើមានថវិកាសល់ពីការដឹកជញ្ជូន ឬការទិញសម្ភារៈ ត្រូវបង្វែរមកប្រើប្រាស់ក្នុងដំណាក់កាលវាយតម្លៃ និងរាយការណ៍នេះ។

## ១.៦. អ្នកទទួលខុសត្រូវក្នុងគម្រោង

ដោយយោងតាម សមាជិកខាងក្រុមយើងខ្ញុំមានចំនួន ៨នាក់ ហើយក៏ជាអ្នកទទួលបន្ទុកក្នុងគម្រោងមួយនេះផងដែរ។ ដូចនេះ អ្នកដែលទទួលខុសត្រូវ បានរៀបរាប់ដូចខាងក្រោម៖

**គោលដៅទី១ ៖**

**សកម្មភាពទី១.១** : បង្កើតក្រុមការងារដែលមានសមាជិក ៨នាក់ ដើម្បីគ្រប់គ្រង និង អនុវត្ត គម្រោង នៅត្រឹមសប្តាហ៍ទី១ ខែកុម្ភៈ ឆ្នាំ២០២៦។

អ្នកទទួលខុសត្រូវសម្រាប់សកម្មភាពទី១.១ អ្នកស្រី ហោ សុគង់

**សកម្មភាពទី១.២** : ក្រុមការងារធ្វើការសិក្សា និងកំណត់ពីតម្រូវការសម្ភារៈជាក់ស្តែងរបស់សិស្សានុ សិស្ស នៅត្រឹមសប្តាហ៍ទី២ ខែកុម្ភៈ ឆ្នាំ២០២៦។

អ្នកទទួលខុសត្រូវសម្រាប់សកម្មភាពទី១.២ កញ្ញា ធិន វល័ក្ខ

**សកម្មភាពទី១.៣** : ក្រុមការងាររៀបចំ និងវេចខ្ចប់កញ្ចប់អំណោយចំនួន ១០០កញ្ចប់សម្រាប់ប្រគល់ជូនសិស្សានុសិស្ស នៅត្រឹមសប្តារហ៍ទី៣ ខែកុម្ភៈ ឆ្នាំ២០២៦។

អ្នកទទួលខុសត្រូវសម្រាប់សកម្មភាពទី១.៣ កញ្ញា ហេង សុបញ្ញា

**គោលដៅទី២ ៖**

**សកម្មភាពទី២.១** : ក្រុមការងារ ដឹកជញ្ជូនកញ្ចប់អំណោយចំនួន១០០ កញ្ចប់ ទៅកាន់ទីតាំងដែល បានកំណត់ នៅត្រឹមសប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២៦។

អ្នកទទួលខុសត្រូវសម្រាប់សកម្មភាពទី២.១ លោក ឡុង សំណាង

**សកម្មភាពទី២.២** : ក្រុមការងាររៀបចំ និងប្រគល់កញ្ចប់អំណោយចំនួន ១០០ កញ្ចប់ ទៅកាន់សិស្សានុសិស្ស នៅត្រឹមសប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២៦។

អ្នកទទួលខុសត្រូវសម្រាប់សកម្មភាពទី២.២ លោក ឆុង វិបុល

**សកម្មភាពទី ២.៣** : ក្រុមការងារ ផ្តិតយករូបភាពយ៉ាងតិច២០០រូប និង វីដេអូអនុស្សាវរីយ៍យ៉ាងតិចចំនួន ១០វីដេអូ នៃសកម្មភាពគម្រោងនៅត្រឹមសប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២៦។

អ្នកទទួលខុសត្រូវសម្រាប់សកម្មភាពទី២.១ កញ្ញា សៀក គឹមហ៊ួង

**គោលដៅទី៣ ៖**

**សកម្មភាពទី៣.១** : ក្រុមការងារធ្វើរបាយការណ៍បូកសរុបថវិកាដែលបានចំណាយសម្រាប់គម្រោង ទាំងមូល នៅត្រឹមសប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២៦ ។

អ្នកទទួលខុសត្រូវសម្រាប់សកម្មភាពទី៣.១ កញ្ញា អោក ម៉ែកណិកា

**សកម្មភាពទី៣.២** : ក្រុមការងារបានធ្វើរបាយការណ៍បូកសរុបនូវលទ្ធផលនានានៃគំរោងនៅត្រឹមសប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២៦។

អ្នកទទួលខុសត្រូវសម្រាប់សកម្មភាពទី៣.២ លោក ចន ប៊ុនជាន

**សកម្មភាពទី៣.៣** : ក្រុមការងារ ប្រគល់របាយការណ៍បូកសរុបចំណាយ និង លទ្ធផលនៃគម្រោង ជូនទៅកាន់អ្នកដែលពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី១ ខែមេសា ឆ្នាំ២០២៦។

អ្នកទទួលខុសត្រូវសម្រាប់សកម្មភាពទី៣.៣ អ្នកស្រី ហោ សុគង់

## ១.៧. សូចនាករ

សូចនាករសម្រាប់វាស់វែង នៅក្នុងគម្រោងនេះរួមមាន ៖

- **គោលដៅទី១** : បង្កើតក្រុមការងារ សិក្សាពីតម្រូវការសម្ភារៈ និង រៀបចំផែនការកម្មវិធីសប្បុរសធម៌ ចាប់ពីសប្តាហ៍ទី១ ខែកុម្ភៈ ឆ្នាំ២០២៦ ដល់ សប្តាហ៍ទី១ ខែមីនា ឆ្នាំ២០២៦។

**សកម្មភាពទី១.១** : បង្កើតក្រុមការងារដែលមានសមាជិក ៨នាក់ ដើម្បីគ្រប់គ្រង និងអនុវត្ត គម្រោង នៅត្រឹមសប្តាហ៍ទី១ ខែកុម្ភៈ ឆ្នាំ២០២៦។

**សូចនាករទី១.១.១** : ការសម្រេចបាននូវសកម្មភាព បង្កើតក្រុមការងារយ៉ាងច្បាស់លាស់ ដោយកំណត់តួនាទី និងភារកិច្ចទៅលើសមាជិករៀងៗខ្លួនដែលនះបញ្ជាក់ថាក្រុមនីមួយៗបានរៀបចំរួចរាល់ជាស្រេចសម្រាប់ការចូលរួមចែកសម្ភារៈសិក្សាតាមតម្រូវការ និងរៀបចំផែនការកម្មវិធីសប្បុរសធម៌នៅត្រឹមសប្តាហ៍ទី១ ខែកុម្ភៈ ឆ្នាំ២០២៦។

**សកម្មភាពទី១.២** : ក្រុមការងារធ្វើការសិក្សា និងកំណត់ពីតម្រូវការសម្ភារៈជាក់ស្តែងរបស់សិស្សានុសិស្ស នៅត្រឹមសប្តាហ៍ទី២ ខែកុម្ភៈ ឆ្នាំ២០២៦។

**សូចនាករទី១.២.១** : ក្រុមការងារចុះទៅដល់ទីតាំងផ្ទាល់ និងជួបពិភាក្សាជាមួយគណៈគ្រប់ គ្រងសាលាដើម្បីពិនិត្យសម្ភារៈដែលមានស្រាប់ និងកំណត់បញ្ជីសម្ភារៈដែលត្រូវការ និងរៀបចំរបាយការណ៍សង្ខេបសម្រាប់ដាក់ជូនអ្នកគ្រប់គ្រង ដើម្បីរៀបចំសម្រាប់ប្រគល់ជូនសិស្សានុសិស្សយ៉ាងយូរត្រឹមសប្តាហ៍ទី ២ ខែកុម្ភៈ ឆ្នាំ២០២៦។

**សកម្មភាពទី១.៣** : ក្រុមការងាររៀបចំ និងវេចខ្ចប់កញ្ចប់អំណោយ ចំនួន ១០០កញ្ចប់ សម្រាប់ប្រគល់ ជូនសិស្សានុសិស្ស នៅត្រឹមសប្តាហ៍ទី៣ ខែកុម្ភៈ ឆ្នាំ២០២៦។

**សូចនាករទី១.៣.១** : ការប្រមូលថវិកាសម្រេចបានជាស្ថាពរ និងកំណត់សកម្មភាពនៃថ្ងៃរៀបចំកម្មវិធី សម្រាប់ប្រគល់កញ្ចប់អំណោយជូនសិស្សានុសិស្ស ត្រឹមៈសប្តារហ៍ទី៣ ខែកុម្ភៈ ឆ្នាំ២០២៦។

- **គោលដៅទី២** : ដឹកជញ្ជូនសម្ភារៈទៅកាន់ទីតាំងរៀបចំកម្មវិធីសប្បុរសធម៌ និង រៀបចំប្រគល់កញ្ចប់អំណោយដល់សិស្សានុសិស្ស និងចូលរួមថតរូបជាអនុស្សាវរីយ៍ ជាមួយលោកគ្រូអ្នកគ្រូ សិស្សានុសិស្សនៅត្រឹមសប្តាហ៍ទី១ ខែមីនា ឆ្នាំ២០២៦។

**សកម្មភាពទី២.១** : ក្រុមការងារ ដឹកជញ្ជូនកញ្ចប់អំណោយ ចំនួន ១០០កញ្ចប់ ទៅកាន់ទីតាំងដែល បានកំណត់ នៅត្រឹមសប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២៦។

**សូចនាករទី ២.១.១** : សម្រេចជាស្ថាពរនូវ ការសិក្សាអំពីតម្លៃថ្លៃដើមនៃធនធានបណ្ណាល័យពីអ្នកផ្គត់ផ្គង់ត្រឹម សប្តាហ៍ទី៣ ខែ កុម្ភៈ ឆ្នាំ២០២៦។

**សកម្មភាពទី២.២** : ក្រុមការងាររៀបចំ និងប្រគល់កញ្ចប់អំណោយ ចំនួន ១០០កញ្ចប់ ទៅកាន់សិស្សានុសិស្ស នៅត្រឹមសប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២៦។

**សូចនាករទី ២.២.១** : សម្រេចជាស្ថាពរនូវដឹកជញ្ជូនសម្ភារៈទៅកាន់ទីតាំងរៀបចំកម្មវិធីសប្បុរសធម៌ តាមពេលវេលាកំណត់នៃកម្មវិធីត្រឹមសប្តាហ៍ទី១ ខែមីនា ឆ្នាំ២០២៦។

**សកម្មភាពទី ២.៣** : ក្រុមការងារ ផ្តិតយករូបភាពយ៉ាងតិច ២០០រូប និងវីដេអូអនុស្សាវរីយ៍យ៉ាងតិចចំនួន១០វីដេអូនៃសកម្មភាពគម្រោងនៅត្រឹមសប្តាហ៍ទី៤ខែមីនាឆ្នាំ២០២៦។

**សូចនាករទី ២.៣.១** : ក្រុមការងារ ផ្តិតយករូបភាព និង វីដេអូអនុស្សាវរីយ៍ដ៏មានន័យ នៃសកម្មភាពគម្រោងត្រឹមសប្តាហ៍ទី១ ខែមីនា ឆ្នាំ២០២៦។

- **គោលដៅទី៣** : បូកសរុបលទ្ធផលការងារ និងចំណាយសម្រាប់ការអនុវត្តគម្រោងទាំងមូល និងសរសេរជារបាយការណ៍សម្រាប់ប្រគល់ជូនភាគីដែលពាក់ព័ន្ធយ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី៣ ខែកុម្ភៈ ឆ្នាំ២០២៦។

**សកម្មភាពទី៣.១** : ក្រុមការងារធ្វើរបាយការណ៍ បូកសរុបថវិកាដែលបានចំណាយសម្រាប់គម្រោងទាំងមូល នៅត្រឹមសប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២៦ ។

**សូចនាករទី ៣.១.១** : សម្រេចជាស្ថាពរនូវបញ្ជីចំណាយសម្រាប់គម្រោងទាំងមូលនៅត្រឹមសប្តាហ៍ទី២ ខែមីនា ឆ្នាំ២០២៦។

**សកម្មភាពទី៣.២** : ក្រុមការងារ ធ្វើរបាយការណ៍បូកសរុបនូវលទ្ធផលនានានៃគម្រោងនៅត្រឹម សប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២៦។

**សូចនាករទី ៣.២.១** : សម្រេចឲ្យបានជាស្ថាពរនូវបញ្ជីលទ្ធផលនៃគម្រោងត្រឹម សប្តាហ៍ទី២ ខែមីនា ឆ្នាំ២០២៦។

**សកម្មភាពទី៣.៣** : ក្រុមការងារ ប្រគល់របាយការណ៍បូកសរុបចំណាយ និងលទ្ធផលនៃគម្រោង ជូនទៅកាន់អ្នកដែលពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី១ ខែមេសា ឆ្នាំ២០២៦។

**សូចនាករទី ៣.៣.១** : សម្រេចបានជាស្ថាពរនូវ របាយការណ៍ចុងក្រោយនៃគម្រោង និងប្រគល់ជូន អ្នកដែលពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី៣ ខែមីនា ឆ្នាំ២០២៦។

## ១.៨. មធ្យោបាយផ្ទៀងផ្ទាត់

មធ្យោបាយផ្ទៀងផ្ទាត់នៅក្នុងគម្រោងនេះរួមមាន ៖

- **គោលដៅទី១** : បង្កើតក្រុមការងារ រួចសិក្សាពីតម្រូវការសម្ភារៈដែលចំបាច់ និង រៀបចំផែនការអំពីកម្មវិធីសប្បុរសធម៌ ចាប់ពីសប្តាហ៍ទី១ ខែកុម្ភៈ ឆ្នាំ២០២៦ ដល់ សប្តាហ៍ទី១ ខែមីនា ឆ្នាំ២០២៦។

**សកម្មភាពទី១.១** : បង្កើតក្រុមការងារដែលមានសមាជិក ៨ នាក់ ដើម្បីគ្រប់គ្រង និងអនុវត្ត គម្រោង នៅត្រឹមសប្តាហ៍ទី១ ខែកុម្ភៈ ឆ្នាំ២០២៦។

**មធ្យោបាយផ្ទៀងផ្ទាត់ទី១.១.១** : ការសម្រេចបាននូវសកម្មភាពបង្កើតក្រុមការងារយ៉ាងច្បាស់លាស់ ដោយកំណត់លើតួនាទី និងភារកិច្ចរបស់សមាជិករៀងៗខ្លួន ដែលបញ្ជាក់ថាក្រុមនីមួយៗបានរៀបចំរួចរាល់សម្រាប់ចូលរួមសិក្សាតម្រូវការសម្ភារៈ និងរៀបចំផែនការកម្មវិធីសប្បុរសធម៌នៅត្រឹមសប្តាហ៍ទី១ ខែកុម្ភៈ ឆ្នាំ២០២៦។

**សកម្មភាពទី១.២** : ក្រុមការងារធ្វើការសិក្សា និងកំណត់ពីតម្រូវការសម្ភារៈជាក់ស្តែងរបស់សិស្សានុសិស្ស នៅត្រឹមសប្តាហ៍ទី២ ខែកុម្ភៈ ឆ្នាំ២០២៦។

**មធ្យោបាយផ្ទៀងផ្ទាត់ទី១.២.១** : ក្រុមការងារចុះទៅដល់ទីតាំងផ្ទាល់ និងជួបពិភាក្សាជាមួយគណៈគ្រប់គ្រងសាលា ដើម្បីពិនិត្យសម្ភារៈដែលមានស្រាប់ និងកំណត់បញ្ជីសម្ភារៈដែលត្រូវការនិងរៀបចំរបាយការណ៍សង្ខេបសម្រាប់ដាក់ជូនអ្នកគ្រប់គ្រង ដើម្បីរៀបចំសម្រាប់ប្រគល់ជូនសិស្សានុសិស្ស យ៉ាងយូរត្រឹមសប្តាហ៍ទី២ ខែកុម្ភៈ ឆ្នាំ២០២៦។

**សកម្មភាពទី១.៣** : ក្រុមការងាររៀបចំ និងវេចខ្ចប់កញ្ចប់អំណោយចំនួន១០០កញ្ចប់សម្រាប់ប្រគល់ ជូនសិស្សានុសិស្ស នៅត្រឹមសប្តាហ៍ទី៣ ខែកុម្ភៈ ឆ្នាំ២០២៦។

**មធ្យោបាយផ្ទៀងផ្ទាត់ទី១.៣.១** : ការប្រមូលថវិកាសម្រេចបានជាស្ថាពរ និងកំណត់សកម្មភាពនៃថ្ងៃរៀបចំកម្មវិធី សម្រាប់ប្រគល់កញ្ចប់អំណោយ ជូនសិស្សានុសិស្សត្រឹមសប្តាហ៍ទី៣ ខែកម្ភៈ ឆ្នាំ២០២៦។

❖ **គោលដៅទី២** : ដឹកជញ្ជូនសម្ភារៈទៅកាន់ទីតាំងរៀបចំកម្មវិធីសប្បុរសធម៌ និង រៀបចំប្រគល់កញ្ចប់អំណោយដល់សិស្សានុសិស្ស និងចូលរួមថតរូបជាអនុស្សាវរីយ៍ ជាមួយលោកគ្រូអ្នកគ្រូសិស្សានុសិស្សនៅត្រឹមសប្តាហ៍ទី១ ខែមីនា ឆ្នាំ២០២៦។

**សកម្មភាពទី២.១** : ក្រុមការងារ ដឹកជញ្ជូនកញ្ចប់អំណោយចំនួន១០០ កញ្ចប់ ទៅកាន់ទីតាំងដែល បានកំណត់ នៅត្រឹមសប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២៦។

**មធ្យោបាយផ្ទៀងផ្ទាត់ទី២.១.១** : សម្រេចជាស្ថាពរនូវ ការសិក្សាអំពីតម្លៃថ្លៃដើមនៃធនធានបណ្ណាល័យពីអ្នកផ្គត់ផ្គង់ត្រឹមសប្តាហ៍ទី ៣ ខែ កុម្ភៈ ឆ្នាំ២០២៦។

**សកម្មភាពទី២.២** : ក្រុមការងាររៀបចំ និងប្រគល់កញ្ចប់អំណោយចំនួន១០០ កញ្ចប់ ទៅកាន់សិស្សា នុសិស្ស នៅត្រឹមសប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២៦។

**មធ្យោបាយផ្ទៀងផ្ទាត់ទី២.២.១** : សម្រេចជាស្ថាពរនូវ ដឹកជញ្ជូនសម្ភារៈទៅកាន់ទីតាំងរៀបចំកម្មវិធីសប្បុរសធម៌ តាមពេលវេលាកំណត់នៃកម្មវិធីត្រឹមសប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២៦។

**សកម្មភាពទី២.៣** : ក្រុមការងារ ផ្ដិតយករូបភាពយ៉ាងតិច២០០រូប និង វីដេអូអនុស្សាវរីយ៍យ៉ាងតិច ចំនួន១០វីដេអូ នៃសកម្មភាពគម្រោងនៅត្រឹមសប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២៦។

**មធ្យោបាយផ្ទៀងផ្ទាត់ទី២.៣.១** : ក្រុមការងារ ផ្ដិតយករូបភាព និង វីដេអូអនុស្សាវរីយ៍ នៃសកម្មភាពគម្រោងក្នុងសប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២៦។

❖ **គោលដៅទី៣** : បូកសរុបលទ្ធផលការងារ និងចំណាយសម្រាប់ការអនុវត្តគម្រោងទាំងមូល និងសរសេរជារបាយការណ៍សម្រាប់ប្រគល់ជូនភាគីដែលពាក់ព័ន្ធយ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី៣ ខែ កុម្ភៈ ឆ្នាំ២០២៦។

**សកម្មភាពទី៣.១** : ក្រុមការងារធ្វើរបាយការណ៍បូកសរុបថវិកា ដែលបានចំណាយសម្រាប់គម្រោង ទាំងមូល នៅត្រឹមសប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២៦ ។

**មធ្យោបាយផ្ទៀងផ្ទាត់ទី៣.១.១** : សម្រេចជាស្ថាពរនូវបញ្ជីចំណាយសម្រាប់គម្រោង ទាំងមូលនៅត្រឹមសប្តាហ៍ ទី ២ ខែ មីនា ឆ្នាំ២០២៦។

**សកម្មភាពទី៣.២** : ក្រុមការងារ ធ្វើរបាយការណ៍បូកសរុបនូវលទ្ធផលនានានៃគម្រោង នៅត្រឹម សប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២៦។

**មធ្យោបាយផ្ទៀងផ្ទាត់ទី៣.២.១** : សម្រេចឲ្យបានជាស្ថាពរនូវ បញ្ជីលទ្ធផលនៃគម្រោង ត្រឹមសប្តាហ៍ទី៣ ខែ មីនា ឆ្នាំ២០២៦។

**សកម្មភាពទី៣.៣** : ក្រុមការងារ ប្រគល់របាយការណ៍បូកសរុបចំណាយ និង លទ្ធផលនៃគម្រោង ជូនទៅកាន់អ្នកដែលពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី១ ខែមេសា ឆ្នាំ២០២៦។

**មធ្យោបាយផ្ទៀងផ្ទាត់ទី ៣.៣.១** : របាយការណ៍ចុងក្រោយនៃគម្រោង និង ប្រគល់ជូនអ្នកដែលពាក់ព័ន្ធ ត្រឹមសប្តាហ៍ទី ៤ ខែមីនា ឆ្នាំ២០២៦។

## ១.៩. ហានិភ័យ

ការអនុវត្តគម្រោងសប្បុរសធម៌នៅក្នុងតំបន់ឆ្នេរនៃស្រុកគិរីសាគរ ខេត្តកោះកុង តម្រូវឱ្យមានការយល់ដឹងស៊ីជម្រៅអំពីបរិបទសង្គម ភូមិសាស្ត្រ និងបទប្បញ្ញត្តិច្បាប់។ ផ្អែកលើផែនការសកម្មភាពដែលអ្នកបានផ្តល់ឱ្យ ខាងក្រោមនេះគឺជាការវិភាគហានិភ័យលម្អិតសម្រាប់សកម្មភាពនីមួយៗ ៖

- **គោលដៅទី១** : បង្កើតក្រុមការងារ សិក្សាពីតម្រូវការសម្ភារៈ និង រៀបចំផែនការកម្មវិធីសប្បុរសធម៌ ចាប់ពីសប្តាហ៍ទី១ ខែកុម្ភៈ ឆ្នាំ២០២៦ ដល់ សប្តាហ៍ទី១ ខែមីនា ឆ្នាំ២០២៦។

**សកម្មភាពទី១.១** : បង្កើតក្រុមការងារដែលមានសមាជិក ៨ នាក់ ដើម្បីគ្រប់គ្រង និងអនុវត្ត គម្រោង នៅត្រឹមសប្តាហ៍ទី១ ខែកុម្ភៈ ឆ្នាំ២០២៦។

**ហានិភ័យ១.១.១** : អាជ្ញធរ គឺមិនមានការសហការជាមួយក្រុមការងារ។

**សកម្មភាពទី១.២** : ក្រុមការងារធ្វើការសិក្សា និងកំណត់ពីតម្រូវការសម្ភារៈជាក់ស្តែងរបស់សិស្សានុសិស្ស នៅត្រឹមសប្តាហ៍ទី២ ខែកុម្ភៈ ឆ្នាំ២០២៦។

**ហានិភ័យ១.២.១** : ព័ត៌មានពីសាលា ឬអាជ្ញាធរ អាចលម្អៀងទៅលើ "តម្រូវការរបស់សាលា" ជាជាង "តម្រូវការផ្ទាល់ខ្លួនរបស់សិស្សក្រីក្រ"។

**សកម្មភាពទី១.៣** : ក្រុមការងាររៀបចំ និងវេចខ្ចប់កញ្ចប់អំណោយចំនួន១០០កញ្ចប់ សម្រាប់ប្រគល់ ជូនសិស្សានុសិស្ស នៅត្រឹមសប្តាហ៍ទី៣ ខែកុម្ភៈ ឆ្នាំ២០២៦។

**ហានិភ័យ១.៣.១** : ការវេចខ្ចប់មិនល្អ ធ្វើឱ្យសម្ភារៈងាយខូចដោយសារទឹកសមុទ្រ ពេលដឹកជញ្ជូនទៅសាលានៅលើកោះ។

- **គោលដៅទី២** : ដឹកជញ្ជូនសម្ភារៈទៅកាន់ទីតាំងរៀបចំកម្មវិធីសប្បុរសធម៌ និង រៀបចំប្រគល់កញ្ចប់អំណោយដល់សិស្សានុសិស្ស និងចូលរួមថតរូបជាអនុស្សាវរីយ៍ ជាមួយលោកគ្រូអ្នកគ្រូ សិស្សានុសិស្សនៅត្រឹមសប្តាហ៍ទី១ ខែមីនា ឆ្នាំ២០២៦។

**សកម្មភាពទី២.១** : ក្រុមការងារ ដឹកជញ្ជូនកញ្ចប់អំណោយចំនួន១០០ កញ្ចប់ ទៅកាន់ទីតាំងដែល បានកំណត់ នៅត្រឹមសប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២៦។

**ហានិភ័យ២.១.១** : ការដ្ឋានពង្រីកផ្លូវជាតិលេខ ៤៨ អាចបង្កជាការកកស្ទះ និងធ្វើឱ្យយឺតយ៉ាវដល់ការជួបជាមួយទូកដឹកជញ្ជូនដែលចេញតាមកាលវិភាគកំណត់ ។

**សកម្មភាពទី២.២** : ក្រុមការងាររៀបចំ និងប្រគល់កញ្ចប់អំណោយចំនួន១០០ កញ្ចប់ ទៅកាន់សិស្សានុសិស្ស នៅត្រឹមសប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២៦។

**ហានិភ័យ២.២.១** : ការកំណត់យកចំនួន ១០០ កញ្ចប់ជាតួលេខមូល អាចបង្កជាហានិភ័យប្រសិនបើចំនួនសិស្សជាក់ស្តែងមានលើសពីនេះ

**សកម្មភាពទី២.៣** : ក្រុមការងារ ផ្តិតយករូបភាពយ៉ាងតិច២០០រូប និង វីដេអូអនុស្សាវរីយ៍យ៉ាងតិច ចំនួន១០ វីដេអូនៃសកម្មភាពគម្រោងនៅត្រឹមសប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២៦។

**ហានិភ័យ២.៣.១** : ការថតរូបដោយមិនមានការសុំការអនុញ្ញាតអាចត្រូវបានចាត់ទុកថាជាការមិនគោរពសិទ្ធិបុគ្គល ។

- **គោលដៅទី៣** : បូកសរុបលទ្ធផលការងារ និងចំណាយសម្រាប់ការអនុវត្តគម្រោងទាំងមូល និងសរសេរជារបាយការណ៍សម្រាប់ប្រគល់ជូនភាគីដែលពាក់ព័ន្ធយ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី៣ ខែ កុម្ភៈ ឆ្នាំ២០២៦។

**សកម្មភាពទី៣.១** : ក្រុមការងារធ្វើរបាយការណ៍បូកសរុបថវិកាដែលបានចំណាយសម្រាប់គម្រោង ទាំងមូល នៅត្រឹមសប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២៦ ។

**ហានិភ័យ៣.១.១** : ដោយសារការចំណាយភាគច្រើនជាប្រាក់ដុល្លារ ប៉ុន្តែរបាយការណ៍ត្រូវដាក់ជូនជាប្រាក់រៀល ការមិនតាមដានអត្រាប្តូរប្រាក់ប្រចាំថ្ងៃរបស់ធនាគារជាតិនឹងធ្វើឱ្យរបាយការណ៍ហិរញ្ញវត្ថុមានកំហុស ។

**សកម្មភាពទី៣.២** : ក្រុមការងារធ្វើរបាយការណ៍បូកសរុបនូវលទ្ធផលនានានៃគម្រោង នៅត្រឹម សប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២៦។

**ហានិភ័យ៣.២.១** : ការធ្វើរបាយការណ៍បូកសរុបនូវលទ្ធផលនានាអាចមានការយឺតយ៉ាវ។

**សកម្មភាពទី៣.៣ :** ក្រុមការងារ ប្រគល់របាយការណ៍បូកសរុបចំណាយ និង លទ្ធផលនៃគម្រោង ជូនទៅកាន់អ្នកដែលពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី១ ខែមេសា ឆ្នាំ២០២៦។

**ហានិភ័យ៣.៣.១ :** ពុំមានអ្នកចូលរួមក្នុងការប្រគល់របាយការណ៍។

# ជំពូកទី២
# ដំណើរការអនុវត្តន៍គម្រោង និងការ
# ជ្រើសរើសធនធានមនុស្ស

# ជំពូកទី២

# ដំណើរការអនុវត្តន៍គម្រោង និងការជ្រើសរើសធនធានមនុស្ស

## ២.១. ការជ្រើសរើសធនធានមនុស្ស

ក្រុមការងារចំនួន ០៨នាក់ ត្រូវបានជ្រើសរើសចេញពីក្រុមនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ ២២ ជំហាន់១ នៃសាលកវិទ្យាសាស្ត្រភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយបានធ្វើការបែងចែកការទទួលខុសត្រូវរៀងៗខ្លួន។

## ២.២. ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៃគម្រោង

ការបែងចែកធនជានមនុស្ស នៅក្នុងគម្រោងស្តីពី ″**កម្មវិធីសប្បុរសធម៌ ទៅកាន់សាលាបឋមសិក្សាដំណាក់ក្របី ឃុំកោះស្តេច ស្រុកគិរីសាគរ ខេត្តកោះកុង**″ មានសមាសភាពដូចខាងក្រោម ៖

**ក. ប្រធានគម្រោង** មានកាតព្វកិច្ច និងទទួលខុសត្រូវដូចជា ៖

- គ្រប់គ្រង ដឹកនាំ និងជួយសម្របសម្រួលទៅដល់ក្រុមការងារ និងភាគីពាក់ព័ន្ធក្នុងគម្រោងទាំងមូល។
- អនុម័តលើផែនការនានា ដូចជាផ្នែកហិរញ្ញវត្ថុ និងផែនការអនុវត្ត រួមទាំងត្រួតពិនិត្យ វាយតម្លៃលទ្ធផលគម្រោងផងដែរ។

**ខ. ផ្នែករៀបចំផែនការ** មានកាតព្វកិច្ច និងទំនួលខុសត្រូវដូចជា ៖

- បែងចែកភារកិច្ចការងារ និងរៀបចំកាលវិភាគ សម្រាប់សមាជិកម្នាក់ៗ។
- តាមដាន និងធ្វើរបាយការណ៍ អំពីវិឌ្ឍនភាពនៃគម្រោងទៅកាន់ប្រធានគម្រោង។

**គ. ផ្នែកហិរញ្ញវត្ថុ** មានកាតព្វកិច្ច និងទំនួលខុសត្រូវដូចជា ៖

- រៀបចំ និងតាមដានផែនការថវិកា និងការចំណាយផ្សេងៗ។
- ត្រួតពិនិត្យ និងរៀបចំរបាយការណ៍ថវិកា និងការចំណាយទៅកាន់ប្រធានគម្រោង។

**ឃ. ផ្នែកទំនាក់ទំនង និងសហប្រតិបត្តិការ** មានកាតព្វកិច្ច និងទំនួលខុសត្រូវដូចជា ៖

- ភ្ជាក់ងារទំនាក់ទំនងទោកាន់ខាងអជ្ញាធរមូលដ្ឋាន អ្នកតំណាងសាលារៀន និងខាងសារពត៌មាននានា។
- ទាក់ទង និងផ្សព្វផ្សាយពត៌មានអំពីសប្បុរសធម៌ និងប្រមូលប្រាក់ឧបត្ថម្ភ។

**ង. ផ្នែកកិច្ចការទូទៅ** មានកាតព្វកិច្ច និងទំនួលខុសត្រូវដូចជា ៖

- រៀបចំសម្ភារៈ ការដឹកជញ្ជូន និងសម្របសម្រួលទៅលើការរៀបចំកម្មវិធីទាំងមូល។

### ២.២.១. ការរៀបចំអង្គការលេខ

អង្គការលេខសម្រាប់គ្រប់គ្រង លើការអនុវត្តន៍គម្រោងស្តីអំពី **កម្មវិធីសប្បុរសធម៌ ទៅកាន់សាលាបឋមសិក្សា ដំណាក់ក្របី ឃុំកោះស្តេច ស្រុកគិរីសាគរ ខេត្តកោះកុង** ត្រូវបានរៀបរៀងឡើងដោយ ៖

# អង្គការលេខនៃគ្រប់គ្រងគម្រោងស្តីអំពី "កម្មវិធីសប្បុរសធម៌ ទៅកាន់សាលាបឋមសិក្សា ដំណាក់ក្របី ស្រុកគិរីសាគរ ខេត្តកោះកុង"

## ប្រធានគម្រោង



**អ្នកស្រី ហោ សុគង់**
លេខទូរស័ព្ទ៖ ០៩៧ ៨៥១ ៩៥១០
អ៊ីម៉ែល៖ sokonghor123@gmail.com

## ផ្នែក រៀបចំផែនការ

### ប្រធានផ្នែក



**កញ្ញា ហេង សុបញ្ញា**
លេខទូរស័ព្ទ៖ ០៨១៦៣៧១៧១
អ៊ីម៉ែល៖ sopanheng327@gmail.com

## ផ្នែក ហិរញ្ញវត្ថុ

### ប្រធានផ្នែក



**កញ្ញា អេង ម៉ៃកណិការ**
លេខទូរស័ព្ទ៖ ០៨៦ ៩២១ ៦១៦
អ៊ីម៉ែល៖ maykanica@gmail.com

### សមាជិក



**លោក ឡុង សំណាង**
លេខទូរស័ព្ទ៖ ០៩៩ ៣៣៣ ៩៣៦
អ៊ីម៉ែល៖ samnanglong723@gmail.com

## ផ្នែក ទំនាក់ទំនង និងសហប្រតិបត្តិការ

### ប្រធានផ្នែក



**កញ្ញា សៀក គីមហ៊ួង**
លេខទូរស័ព្ទ៖ ០៩៦ ៩៣៨ ៥៩៥៩
អ៊ីម៉ែល៖ s.kimhoung11@gmail.com

### សមាជិក



**លោក ឆុង វិបុល**
លេខទូរស័ព្ទ៖ ០៨៩ ៨៦៦ ២៨៨
អ៊ីម៉ែល៖ vibolchhong17@gmail.com

## ផ្នែក កិច្ចការទូទៅ

### ប្រធានផ្នែក



**កញ្ញា ធិន វល្លក្ខ**
លេខទូរស័ព្ទ៖ ០៦៦ ៦១០ ០១៦
អ៊ីម៉ែល៖ thinvoleak016@gmail.com

### សមាជិក



**លោក ចន ប៊ុនធាន**
លេខទូរស័ព្ទ៖ ០៨៨ ៤២៧ ១០៨៤
អ៊ីម៉ែល៖ chornbunthean88@gmail.com

រៀបចំដោយ

**លោក ចន ប៊ុនធាន**
សមាជិកផ្នែក កិច្ចការទូទៅ
កាលបរិច្ឆេទ៖ ២០/០១/២០២៦

អនុម័តដោយ

**អ្នកស្រី ហោ សុគង់**
ប្រធានគម្រោង
កាលបរិច្ឆេទ៖ ២២/០១/២០២៦

### ២.២.២. តួនាទី និងទំនួលខុសត្រូវ

ក្រុមការងារចំនួន ៨នាក់ បានធ្វើការបែងចែងតួនាទី និងភារកិច្ចទទួលខុសត្រូវដូចខាងក្រោម ៖

| ល.រ | គោត្តនាម និងនាម | តួនាទី | | ភារកិច្ចទទួលខុសត្រូវ |
|---|---|---|---|---|
| ១ | អ្នកស្រី ហោ សុគង់ | ប្រធានគម្រោង | | -បង្កើតក្រុមការងារដែលមានសមាជិក ៨ នាក់ ដើម្បីគ្រប់គ្រង និង អនុវត្ត គម្រោង<br>-ក្រុមការងារ ប្រគល់របាយការណ៍បូកសរុបចំណាយ និងលទ្ធផលនៃគម្រោង ជូនទៅកាន់អ្នកដែលពាក់ព័ន្ធ |
| ២ | កញ្ញា ហេង សុបញ្ញា | ប្រធានផ្នែក | ផ្នែក រៀបចំផែនការ | ក្រុមការងាររៀបចំ និងវេចខ្ចប់កញ្ចប់អំណោយចំនួន១០០កញ្ចប់ សម្រាប់ប្រគល់ ជូនសិស្សានុសិស្ស |
| ៣ | កញ្ញា អោក ម៉ែ កណិការ | ប្រធានផ្នែក | ផ្នែក ហិរញ្ញវត្ថុ | ក្រុមការងារធ្វើរបាយការណ៍បូកសរុបថវិកា ដែលបានចំណាយសម្រាប់គម្រោង ទាំងមូល |
| ៤ | លោក ឡុង សំណាង | សមាជិក | | ក្រុមការងារ ដឹកជញ្ជូនកញ្ចប់អំណោយចំនួន ១០០ កញ្ចប់ ទៅកាន់ទីតាំងដែល បានកំណត់ |
| ៥ | កញ្ញា សៀក គីមហ៊ួង | ប្រធានផ្នែក | ផ្នែក ទំនាក់ទំនង និង សហប្រតិបត្តិការ | ក្រុមការងារ ផ្តិតយករូបភាពយ៉ាងតិច ២០០រូប និង វីដេអូ អនុស្សាវរីយ៍យ៉ាងតិចចំនួន ១០វីដេអូ នៃសកម្មភាពគម្រោង |
| ៦ | លោក ធុង វិបុល | សមាជិក | | ក្រុមការងាររៀបចំ និងប្រគល់កញ្ចប់អំណោយចំនួន ១០០ កញ្ចប់ ទៅកាន់សិស្សានុសិស្ស |
| ៧ | កញ្ញា ជិន វល្លក្ខ | ប្រធានផ្នែក | ផ្នែក កិច្ចការទូទៅ | ក្រុមការងារធ្វើការសិក្សា និងកំណត់ពីតម្រូវការសម្ភារៈជាក់ស្តែងរបស់សិស្សានុ សិស្ស |
| ៨ | លោក ចន ប៊ុនជាន | សមាជិក | | ក្រុមការងារ ធ្វើរបាយការណ៍បូកសរុបនូវលទ្ធផលនានានៃគម្រោង |

### ២.២.៣. ការប្រើប្រាស់ពេលវេលា

គម្រោងនេះ ត្រូវចំណាយពេលវេលាសម្រាប់ ការអនុវត្តរយៈពេល ៖

| ល.រ | ផែនការសកម្មភាព | ចំនួនថ្ងៃ | ថ្ងៃចាប់ផ្តើម | ថ្ងៃបញ្ចប់ | ខែកុម្ភៈ ឆ្នាំ២០២៦ | | | | ខែមីនា ឆ្នាំ២០២៦ | | | | ខែមេសា ឆ្នាំ២០២៦ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | សប្តាហ៍ | | | | សប្តាហ៍ | | | | សប្តាហ៍ | | | |
| | | | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ១ | បង្កើតក្រុមការងារ សិក្សាពីតម្រូវការសម្ភារៈ និង រៀបចំផែនការកម្មវិធីសប្បុរសធម៌ លើកគម្រោងចំណាយឱ្យហើយមុន ដំណាច់ខែកុម្ភៈ ឆ្នាំ២០២៦ | ២៨ | ១/២/២០២៦ | ១/៣/២០២៦ | | | | | | | | | | | | |
| ១.១ | បង្កើតក្រុមការងារដែលមានសមាជិក ៨ នាក់ ដើម្បីគ្រប់គ្រង និងអនុវត្តគម្រោង នៅត្រឹមសប្តាហ៍ទី១ ខែកុម្ភៈ ឆ្នាំ២០២៦ | ៧ | ១/២/២០២៦ | ៧/២/២០២៦ | | | | | | | | | | | | |
| ១.២ | ក្រុមការងារធ្វើការសិក្សា និងកំណត់ពីតម្រូវការសម្ភារៈជាក់ស្តែងរបស់ សិស្សានុសិស្ស នៅត្រឹមសប្តាហ៍ទី២ ខែកុម្ភៈ ឆ្នាំ២០២៦ | ៧ | ៨/២/២០២៦ | ១៤/២/២០២៦ | | | | | | | | | | | | |
| ១.៣ | ក្រុមការងាររៀបចំ និងវេចខ្ចប់កញ្ចប់អំណោយចំនួន១០០កញ្ចប់សម្រាប់ប្រគល់ ជូនសិស្សានុសិស្ស នៅត្រឹមសប្តាហ៍ទី៣ ខែកុម្ភៈ ឆ្នាំ២០២៦ | ២១ | ១៥/២/២០២៦ | ០១/៣/២០២៦ | | | | | | | | | | | | |
| ២ | ដឹកជញ្ជូនសម្ភារៈធ្វើដំណើរទៅកាន់ទីតាំងដែលបានកំណត់ និង រៀបចំកម្មវិធី ប្រគល់កញ្ចប់អំណោយដល់សិស្សានុសិស្ស នៅត្រឹម សប្តាហ៍ទី ២ ខែ មីនា ឆ្នាំ ២០២៦ | ១៤ | ៨/៣/២០២៦ | ២២/៣/២០២៦ | | | | | | | | | | | | |
| ២.៣ | ក្រុមការងារផ្តិតយករូបភាពយ៉ាងតិច២០០រូប និងវីដេអូអនុស្សាវរីយ៍យ៉ាងតិច ចំនួន១០វីដេអូនៃសកម្មភាពគម្រោងនៅត្រឹមសប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២៦។ | ៧ | ១៥/៣/២០២៦ | ២២/៣/២០២៦ | | | | | | | | | | | | |
| ៣ | សរសេររបាយការណ៍អំពី ការចំណាយ និងលទ្ធផលនានានៃគម្រោង ដើម្បីដាក់ ជូន ទៅកាន់អ្នកពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី៤ ខែ មីនា ឆ្នាំ២០២៦ | ៧ | ២៣/៣/២០២៦ | ៣០/៣/២០២៦ | | | | | | | | | | | | |
| ៣.១ | ក្រុមការងារធ្វើរបាយការណ៍បូកសរុបថវិកា ដែលបានចំណាយសម្រាប់គម្រោង ទាំងមូល នៅត្រឹមសប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២៦ | ៧ | ២៣/៣/២០២៦ | ៣០/៣/២០២៦ | | | | | | | | | | | | |
| ៣.២ | ក្រុមការងារ ធ្វើរបាយការណ៍បូកសរុបនូវលទ្ធផលនានានៃគម្រោង នៅត្រឹម សប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២៦ | ៧ | ២៣/៣/២០២៦ | ៣០/៣/២០២៦ | | | | | | | | | | | | |
| ៣.៣ | ក្រុមការងារ ប្រគល់របាយការណ៍បូកសរុបចំណាយ និង លទ្ធផលនៃគម្រោងជូន ទៅកាន់អ្នកដែលពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី១ ខែមេសា ឆ្នាំ២០២៦។ | ៧ | ១/៤/២០២៦ | ០៧/៤/២០២៦ | | | | | | | | | | | | |

## ២.៤ ការប្រើប្រាស់ប្រធានគម្រោង

ថវិការគម្រោងទទួលបានពីប្រភពថវិការទាំងពីរខាងលើនឹងត្រូវបែងចែកសម្រាប់ការងារផ្សេងៗដូចខាងក្រោម ៖

| ល.រ | មុខទំនិញ | ចំនួន | តម្លៃ/ឯកតា (រៀល) | សរុប (រៀល) | ភាគរយ | ភ្នាក់ងារ/មធ្យោបាយ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១ | កាបូបស្ពាយសិស្ស | ១ រង់ | ២៤ ០០០ | ២ ៤០០ ០០០ | | | សម្រាប់សិស្សបឋម |
| ២ | សៀវភៅសរសេរ | ៥ ក្បាល | ៥ ០០០ | ៥០០ ០០០ | | | ខ្នាត A៥ |
| ៣ | ឈុតសម្ភារៈ (ប៊ិច, ខ្មៅដៃ, ជ័រលុប, បន្ទាត់) | ១ ឈុត | ៣ ០០០ | ៣០០ ០០០ | | | ឈុតសិក្សាមូលដ្ឋាន |
| ៤ | ការវេចខ្ចប់ និងស្ទីកគ័រឡូហ្គោ | ១ កញ្ចប់ | ២ ០០០ | ២០០ ០០០ | | | ការពារជម្រាបទឹក |
| ៥ | **សរុបថវិកាសម្រាប់សម្ភារៈ** | | **៣៤ ០០០** | **៣ ៤០០ ០០០** | **៤២,៥%** | | **ថវិកានិស្សិត** |
| ៦ | ឡានក្រុង (ភ្នំពេញ - គិរីសាគរ | ១គ្រឿង | ២ ៤០០ ០០០ | ២ ៤០០ ០០០ | | ឡានក្រុង ៣២ កៅអី (ជួល៣ ថ្ងៃ) | ដឹកក្រុមការងារ និងសម្ភារៈ |
| ៧ | ទូកដឹកសម្ភារៈ និងក្រុមការងារ | ៣ទូក | ៣៥០ ០០០ | ៣៥០ ០០០ | | ទូកសហគមន៍/អ្នកស្រុក | សម្រាប់ឆ្លងទៅសាលាបឋមសិក្សា ដំណាក់ក្របី |
| ៨ | **សរុបរួមការដឹកជញ្ជូន** | ៤ | | **២ ៧៥០ ០០០** | **៣៤,៤%** | | **ថវិកាសប្បុរសជន** |
| ៩ | **ប្រាក់ឧបត្ថម្ភផ្ទាល់ជូនសាលារៀន** | | | **១ ៤៥០ ០០០** | **១៨,១%** | | **ថវិកាសេសសល់ពីសប្បុរសជន** |
| ១០ | **ថវិកាបម្រុងរដ្ឋបាល (៥%)** | | | **៤០០ ០០០** | **០,៨%** | | **របាយការណ៍/សេវាសាធារណៈ** |
| ១១ | **សរុបថវិកាគម្រោង** | | | **៨ ០០០ ០០០** | **១០០%** | | |

**កំណត់សំគាល់៖** ទឹកប្រាក់សរុបស្មើនឹង៨ ០០០ ០០០រៀល។(ស្មើនឹង១ ៩៥១,២១ដុល្លាអាមេរិចអត្រាប្តូរប្រាក់ ១USD = ៤ ១០០KHR)។

## ២.៥. ការតាមដានត្រួតពិនិត្យគម្រោង

### ២.៥.១. ការតាមដានគម្រោង

ការតាមដានទៅលើសកម្មភាពដែលបានកំណត់ក្នុងការអនុវត្ត ថាបានដំណើរការទៅតាមផែនការ និងពេលវេលាកំណត់ឬទេត្រូវធ្វើឡើងនៅក្នុងកំឡុងអនុវត្តគម្រោងដោយប្រធានផ្នែករៀបចំផែនការនៃគម្រោង។ លើសពីនេះទៅទៀត ការតាមដានគម្រោងនេះ គឺដើម្បីធានាថា ដំណើរការនៅតែរលូនទៅតាមផែនការដែលបានដាក់ចេញឱ្យអនុវត្ត។

ចំពោះការតាមដានគម្រោង នឹងត្រូវប្រើប្រាស់កញ្ចប់ថវិកាផ្ទាល់ខ្លួនរបស់អ្នកតាមដាន ដោយចាត់ទុកជាសកម្មភាពស្ម័គ្រចិត្តសម្រាប់គម្រោង។

### ២.៥.២. ការវាយតម្លៃគម្រោង

ការវាយតម្លៃគម្រោង ត្រូវធ្វើឡើងនៅចុងបញ្ចប់នៃគម្រោង ដោយប្រធានគម្រោងផ្ទាល់។ ក្នុងន័យនេះប្រធានគម្រោងនឹងដឹកនាំកិច្ចប្រជុំពិនិត្យ និងវាយតម្លៃ ដែលកិច្ចប្រជុំនេះត្រូវមានសមាសភាពសមាជិកនៃគម្រោងទាំងអស់ ដើម្បីវាយតម្លៃទៅលើលទ្ធភាពនៃសកម្មភាព ថាបានឆ្លើយតបទៅគោលបំណង និងការរំពឹងទុករបស់គម្រោងនេះ។ ជាមួយគ្នានេះ ការតាមដានគ្រប់ដំណាក់កាលទាំងអស់នៃគម្រោង នឹងត្រូវបានកត់ត្រាទុកជាឯកសារ និងវាស់ស្ទង់នូវកម្រិតពេញចិត្ត និងទាន់ពេលវេលានៃសកម្មភាពនីមួយៗតាមពីការចាប់ផ្តើមគម្រោង រហូតដល់បញ្ចប់គម្រោង។

ចំពោះការវាយតម្លៃគម្រោងនឹងត្រូវប្រើប្រាស់កញ្ចប់ថវិកាផ្ទាល់ខ្លួនរបស់ប្រធានគម្រោង និង ក្រុមការងារ ដោយចាត់ទុកជាសកម្មភាពស្ម័គ្រចិត្តសម្រាប់គម្រោង។

ការវាយតម្លៃគម្រោង គឺធ្វើឡើងចំនួន ៤ដំណាក់កាល ៖

១. Pre-Evaluation គឺអំឡុងពេលការអង្កេតតម្រូវការសម្ភារៈ ការពិនិត្យធនធាន និងវិភាគលើបញ្ហាដែលអាចកើតមាន។

២. On-going Evaluation គឺអំឡុងពេលដំណើរការគ្រប់គ្រងសកម្មភាព ការដោះស្រាយបញ្ហាចំពោះមុខ ផ្ទៀងផ្ទាត់ការចំណាយលើសម្ភារៈ និងមធ្យោបាយធ្វើដំណើរឱ្យស្របតាមកញ្ចប់ថវិកា។

៣. End-Evaluation គឺធ្វើឡើងភ្លាមៗបន្ទាប់ពីបញ្ចប់សកម្មភាព គឺការសម្រេចគោលដៅការពេញចិត្តពីអ្នកចូលរួម និងបូកសរុបចំណូល-ចំណាយសរុបភ្លាមៗក្រោយបញ្ចប់កម្មវិធី។

៤. Post-Evaluation គឺការវាយតម្លៃលើផលប៉ះពាល់ និងមេរៀនដែលទទួលបានគឺកត់ត្រានូវចំណុចខ្លាំង និងចំណុចខ្សោយ ដើម្បីទុកជាបទពិសោធន៍សម្រាប់គម្រោងក្រោយ និង ផ្ញើរបាយការណ៍លទ្ធផល និងរូបភាពទៅកាន់អ្នកបរិច្ចាក ដើម្បីបង្កើតទំនុកចិត្ត។

#### ២.៥.៣. ការតាមដានបន្ត

ការតាមដានបន្ត ត្រូវធ្វើឡើងនៅរយៈពេល ១ខែ បន្ទាប់ពីគម្រោងត្រូវបានបញ្ចប់ ដោយប្រធានគម្រោង ដើម្បីតាមដានមើលនូវប្រសិទ្ធិភាព និងនិរន្តរភាពនៃគម្រោងដែលបានអនុវត្ត អាចជះឥទ្ធិពលកម្រិតណាទៅលើជីវភាព និងទឹកចិត្តរបស់សិស្សានុសិស្សនៅក្នុងសាលាបឋមសិក្សាជំណាក់ក្របី ស្រុកគិរីសាគរ ខេត្តកោះកុង។

ចំពោះការតាមដានបន្តនឹងត្រូវប្រើប្រាស់កញ្ចប់ថវិកាផ្ទាល់ខ្លួនរបស់ប្រធានគម្រោងដោយចាត់ទុកជាសកម្មស្ម័គ្រចិត្តសម្រាប់គម្រោង។

### ២.៦. ការបញ្ចប់គម្រោង

#### ២.៦.១. ការបញ្ចប់គម្រោង

គម្រោង"**កម្មវិធីសប្បុរសធម៌ទៅកាន់ សាលាបឋមសិក្សាជំណាក់ក្របី ឃុំកោះស្តេច ស្រុកគិរីសាគរ ខេត្តកោះកុង**" មានរយៈពេល ៦៦ថ្ងៃ ដោយគិតចាប់ពីសប្តាហ៍ទី១ ខែកុម្ភៈ ឆ្នាំ២០២៦ ដល់សប្តាហ៍ទី១ ខែមេសា ឆ្នាំ២០២៦។ គម្រោងសប្បុរសធម៌ទៅខេត្តកោះកុងនេះ បានសម្រេចគោលបំណងក្នុងការជួយសិស្សានុសិស្សដែលរស់នៅតំបន់ក្រីក្រ។ តាមរយៈការរៀបចំដោយមានផែនការ ការចូលរួមយ៉ាងសកម្មពីអ្នកពាក់ព័ន្ធ និងការអនុវត្តដែលមានប្រសិទ្ធភាព ក្រុមការងារគម្រោងនឹងទទួលបាននូវបទពិសោធន៍ និងចំណេះដឹងក្នុងការធ្វើផែនការគម្រោង រៀបចំចាត់ចែងភារៈកិច្ចទំនួលខុសត្រូវរួមទាំងធនធាននានា ការទំនាក់ទំនងសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធ និងការតាមដាន ព្រមទាំងវាយតម្លៃគម្រោងដោយផ្ទាល់។ ម្យ៉ាងទៀតសមាជិកគម្រោង នឹងទទួលបាននូវការស្វែងយល់ជាក់ស្តែងអំពីស្ថានភាពអប់រំដែលមានកម្រិត នៅក្នុងស្រុកគិរីសាគរ ខេត្តកោះកុងផងដែរ។

#### ២.៦.២. ការផ្ទេរនិរន្តភាពនៃគម្រោង

ក្រោយពីគម្រោងបានបញ្ចប់ ដើម្បីធានានូវទិន្នន័យលទ្ធផលដែលប្រមូលបានពីការអនុវត្តគម្រោង ក្រុមការងារគម្រោងសម្រេចផ្ញើជូនអ្នកពាក់ព័ន្ធទាំងអស់នូវរបាយការណ៍របស់គម្រោង ដើម្បីធានាឱ្យបាននូវតម្លាភាពនៃគម្រោង។ លើសពីនេះទៅទៀត ដើម្បីជាឯកសារយោង និងព័ត៌មានទាក់ទងទៅនឹងស្ថានភាពជាក់ស្តែងរបស់សិស្សានុសិស្សនៅស្រុកគិរីសាគរ ខេត្តកោះកុងផងនេះ សម្រាប់ជាគោលដៅសកម្មភាពសប្បុរសធម៌នាពេលអនាគត ក្រុមការងារនឹងផ្សព្វផ្សាយរបាយការណ៍របស់គម្រោងជាសាធារណៈ នៅលើគេហទំព័រផ្លូវការរបស់សកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងក្នុងប្រព័ន្ធទំនាក់ទំនងសង្គមនានា។ ជាមួយនឹងការចែករំលែករបាយការណ៍នេះ នឹងក្លាយជាគំរូ និងបំផុសគំនិតដល់អ្នកជំនាន់ក្រោយក្នុងការរៀបចំព្រមទាំងអនុវត្តសកម្មភាពសប្បុរសធម៌ក្នុងសង្គមនាអនាគត។

# ជំពូកទី៣

# ការវិភាគ SWOT លើដំណើរការ

# អនុវត្តន៍គំរោង

# ជំពូកទី៣

# ការវិភាគ SWOT លើដំណើរការអនុវត្តន៍គំរោង

គម្រោង "**កម្មវិធីសប្បុរសធម៌ទៅកាន់ សាលាបឋមសិក្សា ដំណាក់ក្របី ឃុំកោះស្ដេច ស្រុកគិរីសាគរ ខេត្តកោះកុង**" គឺជាកម្មវិធីសប្បុរសធម៌ ដែលមាន ចូលរួមមូលនិធិសប្បុរសធម៌ សំណាក់និស្សិតថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ ឯកទេសគ្រប់គ្រង ជំនាន់ទី២២ ជំហាន១ (MBM22-1B)នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសប្បុរសជនដទៃ ដែលមានគោលបំណង ដើម្បីចូលរួមជួយសម្រួលដល់ជីវភាព និងលើកទឹកចិត្តសិស្សានុសិស្សនៅក្នុងឃុំកោះស្ដេច ខេត្តកោះកុងតាមរយៈការផ្ដល់អំណោយសប្បុរសធម៌ជាសម្ភារៈសិក្សាដែលចាំបាច់ និងថវិកាសម្រាប់ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀន។ ជាមួយគ្នានេះដែរ ក្នុងការអភិវឌ្ឍន៍គម្រោង ការវិភាគ SWOT លើដំណើរការអនុវត្តគម្រោងរួមមានដូចខាងក្រោម ៖

## ៣.១. ចំណុចខ្លាំង

- ការបែងចែកក្រុមការងារគ្រប់គ្រងអនុវត្ត : ការបង្កើតក្រុមការងារ ជួយឲ្យមានការបែងចែកភារកិច្ចច្បាស់លាស់ហើយជួយឲ្យការងារមានភាពងាយស្រួល និងប្រកបដោយរលូន។
- កាលវិភាគអនុវត្តគម្រោងមានរចនាសម្ព័ន្ធច្បាស់លាស់ : គម្រោងមានការរៀបចំល្អជាមួយនឹងកាលបរិច្ឆេទកំណត់សម្រាប់សកម្មភាពនីមួយៗ ដែលវាជួយឲ្យក្រុមការងារ អាចគ្រប់គ្រងពេលវេលាឲ្យមានប្រសិទ្ធភាព និងគ្រប់គ្រងការអនុវត្តស្របតាមផែនការ។
- ការប្រើប្រាស់ឯកសារ និងឧបករណ៍ជំនួយ : ប្រើប្រាស់ឯកសារយោង (លិខិតស្នើសុំ លិខិតអនុញ្ញាត របាយការណ៍ពាក់ព័ន្ធ រូបថត និង វីដេអូនៃសកម្មភាពគម្រោង) ដើម្បីបញ្ជាក់ថាសកម្មភាពបានអនុវត្ត ជាក់ស្តែង និងជួយបង្ហាញពីភាពមានទំនួលខុសត្រូវនៃគម្រោងដើម្បីទុកជូនភាគីដែលពាក់ព័ន្ធ ។
- ការទំនាក់ទំនង : សមាជិកគម្រោងមានទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធ រួមមានអ្នកឧបត្ថម្ភអាជ្ញាធរមូលដ្ឋានគណៈគ្រប់គ្រងសាលាដែលអាចសម្រួលដល់ការរៀបចំផែនការ ប្រមូលប្រាក់ឧបត្ថម្ភ និងអនុវត្តកម្មវិធីនៅនឹងទីតាំងផ្ទាល់។
- បេសកកម្មសប្បុរសធម៌ដ៏មានអត្ថន័យ : គម្រោងផ្តោតលើការជួយសម្រួលដល់ជីវភាសិស្សានុសិស្សក្រីក្រដែលវាមិនមែនត្រឹមតែជាបេសកកម្មដែលមានអត្ថន័យប៉ុណ្ណោះទេ វាថែមទាំងជួយទាក់ ទាញចិត្តសប្បុរសធម៌ឲ្យមានការចូលរួមកាន់តែច្រើន និងជំរុញឲ្យអ្នកស្ម័គ្រចិត្ត និងអ្នកឧបត្ថម្ភចូលរួមយ៉ាងសកម្មផងដែរ។

## ៣.២. ចំណុចខ្សោយ

- មូលនិធិសប្បុរសនៅមានកម្រិត : ដោយសារការប្រមូលមូលនិធិមានរយៈពេលខ្លី ដែលតម្រូវឱ្យកញ្ចប់អំណោយសប្បុរស និង ថវិកាឧបត្ថម្ភ នៅមានកម្រិតតិចតួច បើធៀបទៅនឹងកង្វះខាតជាក់ស្តែងដែលគម្រោងបានស្វែងយល់។
- ពឹងផ្អែកលើអ្នកស្ម័គ្រចិត្ត : ការអនុវត្តសកម្មភាពជាច្រើនត្រូវពឹងផ្អែកលើអ្នកស្ម័គ្រចិត្ត ប្រសិនបើអ្នកស្ម័គ្រចិត្តមិនអាចចូលរួមបាន នឹងបណ្តាលឲ្យមានការពន្យារពេល ឬការរំខាន។
- ការត្រួតពិនិត្យនៅមានកម្រិត : ដោយសារ ចំនួនសមាជិកគម្រោងមានកម្រិតតិចតួច បើធៀបទៅនឹង ចំនួនច្រើននៃអ្នកចូលរួម រួមបញ្ចូលនិស្សិតមកពីក្រុងភ្នំពេញ និង អ្នកចូលរួមផ្ទាល់នៅក្នុងតំបន់បាន ធ្វើឱ្យមានចន្លោះខ្វះខាតមួយចំនួន ក្នុងការត្រួតពិនិត្យគុណភាពការងារ។
- ការលំបាកក្នុងការទំនាក់ទំនងជាមួយសហគមន៍ : អាចមានបញ្ហាភាសា ឬវប្បធម៌ ខណៈពេលធ្វើការជាមួយសហគមន៍ជនបទ ដែលវាអាចមានផលប៉ះពាល់ដល់ការយល់ដឹងអំពីតម្រូវការ និងការសម្របសម្រួលសកម្មភាពនានា។
- ហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់គោលដៅ និងអាកាសធាតុ : ស្ថានភាពផ្លូវធ្វើដំណើរអាចមិនសូវល្អ ឬស្ថានភាពអាកាសធាតុអាចបណ្តាលឲ្យពន្យារពេលការដឹកជញ្ជូនសម្ភារៈ និងការទៅដល់គោលដៅតាមពេលវេលាកំណត់។

## ៣.៣. ឱកាស

- ពង្រីកទំនាក់ទំនង : បង្កើនភាពជិតស្និតរវាងក្រុមការងារគម្រោងគណៈគ្រប់គ្រងសាលា សិស្សានុសិស្ស និងអជ្ញាធរក្នុងតំបន់។
- ពង្រឹងគុណភាពអប់រំ : ផ្តល់លទ្ធភាពជាសំភារៈ សំរាប់សិស្សានុសិស្ស ក្នុងការបន្តការសិក្សាដែលនៅតំបន់ដាច់ស្រយាល។
- យុវជន និងសកម្មភាពសង្គម : ផ្តល់ឱកាស និងលើកទឹកចិត្តដល់ក្រុមយុវជនឲ្យចូលរួមការងារសង្គម។
- ការផ្សព្វផ្សាយ : បង្ហាញសកម្មភាពវិជ្ជមាននៃការងារសង្គម ដែលអាចជំរុញដល់អ្នកដែលមានចំណាប់អារម្មណ៍ចង់បរិច្ចាកនាពេលអនាគតអោយបានច្រើន ។

## ៣.៤. ការគំរាមកំហែង

- លក្ខខណ្ឌកង្វះយានយន្តក្នុងការដឹកជញ្ជូន : ដោយសារការធ្វើដំណើរ គឺប្រើប្រាស់យានយន្តផ្ទាល់ខ្លួនរបស់សមាជិកក្នុងក្រុម ដូច្នេះអាចផ្តល់ផលវិបាក ក្នុងការដឹកជញ្ជូនសំភារៈផ្សេងៗ ដោយសារទំហំផ្ទុកមានកំរិត។
- លក្ខខណ្ឌផ្លូវក្នុងការដឹកជញ្ជូន : ដោយសារទីតាំងនៅតំបន់កោះដែលនៅជាប់ដែនសមុទ្រ អាចបង្កផលលំបាកក្នុងដឹកជញ្ជូនសម្ភារៈ និងតំរូវអោយមានមធ្យាបាយដឹកតាមទឹកអោយបានត្រឹមត្រូវ។
- លក្ខខណ្ឌសុវត្ថិភាព : ដោយសារការធ្វើដំណើររបស់ក្រុមការងារ តម្រូវតាមផ្លូវគោក និងផ្លូវទឹក ក្នុងនោះដែរ គឺមានក្រុមការងារយើងមួយចំនួនមិនចេះហែលទឹក និងពុលរលក។
- លក្ខខណ្ឌវប្បធម៌ និងការរស់នៅ : វាអាចមានភាពខុសគ្នាខ្លះ រវាងក្រុមការងារ និងប្រជាជនក្នុងតំបន់ដែលអាចនឹងអោយមានភាពភ័ណ្ឌច្រឡំផ្សេងៗ។
- លក្ខខណ្ឌកង្វះទំនុកចិត្តនៃអ្នកបរិច្ចាក : អាចមានករណីមិនទុកចិត្ត ទៅលើការប្រើប្រាស់កញ្ចប់ថវិកាក្នុងការទិញសម្ភារៈផ្សេងៗ ។

# សេចក្តីសន្និដ្ឋាន

ក្រោយពេលអនុវត្តន៍គម្រោងមួយនេះចប់រួចរាល់ គម្រោងនេះបានបង្ហាញភាពជោគជ័យយ៉ាងច្បាស់លាស់ ទាំងនៅក្នុងការធ្វើផែនការ ការអនុវត្តន៍ ការតាមដាន និងការវាយតំលៃគម្រោង។ ម្យ៉ាងវិញទៀត ការចូលរួមយ៉ាងសកម្មពីសមាជិកក្នុងគម្រោង និងការគាំទ្រពីសហគមន៍ ក្នុងតំបន់បានជះឥទ្ធិពលវិជ្ជមានយ៉ាងខ្លាំងទៅលើសិស្សានុសិស្ស នៅសាលាបឋមសិក្សាដែលជាគោលដៅនៃគម្រោង។

លទ្ធផលវិជ្ជមានដែលទទួលបានពីគម្រោងមួយនេះ មានដូចជា ៖

- ការចែកសម្ភារៈសិក្សា បរិក្ខារសាលារៀន និងឧបត្ថម្ភផ្សេងៗទៅដល់សិស្សានុសិស្សដែលកំពុងខ្វះខាត
- បង្កើតទំនាក់ទំនង និងបន្សល់នូវអនុស្សាវរីយ៍ និងទំនាក់ទំនងល្អៗ ជាមួយ សហគមន៍ក្នុងតំបន់
- ការលើកកម្ពស់សមត្ថភាពការងារជាក្រុម និងភាពដឹកនាំរបស់និស្សិត នៅក្នុងសហគមន៍ជាក់ស្តែង
- បន្ថែមលើសពីនេះទៅទៀតគម្រោងមួយនេះបានផ្តល់ឱកាសដល់ក្រុមនិស្សិត ក្នុងការអនុវត្តន៍និងបង្កើនចំណេះដឹងអំពីការរៀបចំ និងគ្រប់គ្រងគម្រោង ការអភិវឌ្ឍន៍ជំនាញទំនាក់ទំនង និងភាពជាអ្នកដឹកនាំ។ បើទោះជាមានឧបសគ្គខ្លះៗ កំឡុងដំណើរការគម្រោងដូចដែលបានរៀបរាប់ខាងលើក៏ក្រុមសមាជិករៀបចំគម្រោងនៅតែបន្តការងារ និងបញ្ចប់ទៅបានយ៉ាងរលូន ។

សរុបសេចក្តីមក គម្រោងមួយនេះបានបង្ហាញពី ការរៀបចំការងារជាក្រុម ដែលផ្តើមចេញពីការស្ម័គ្រចិត្តរបស់ក្រុមសមាជិកគ្រប់រូប ដែលអាចជាជំនួយមួយផ្នែក ដល់សហគមន៍ ជាពិសេសសាលារៀន ដែលការងារមួយនេះបានឆ្លុះបញ្ចាំង និងជាគំរូល្អសម្រប់គម្រោងសប្បុរសធម៌ផ្សេងៗទៀតនាពេលអនាគត។